មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៣

# អញ្ញសមានាចេតសិក ១៣ ចែកជាពីរពួក

## សព្វចិត្តសាធារណចេតសិក ៧

| | |
|---|---|
| ១- ផស្សៈ | ការប៉ះខ្ទប់ |
| ២- វេទនា | ការសោយអារម្មណ៍ |
| ៣- សញ្ញា | ការចងចាំ |
| ៤- ចេតនា | ការតាំងចិត្ត |
| ៥- ឯកគ្គតា | ការមិនរវើរវាយ |
| ៦- ជីវិតិន្ទ្រិយ | ការរក្សាសហជាតធម៌ |
| ៧- មនសិការៈ | ការរួបរួមសហជាតធម៌ |

## បកិណ្ណកចេតសិក ៦

| | |
|---|---|
| ១- វិតក្កៈ | ការលើកចិត្តឡើងកាន់អារម្មណ៍ |
| ២- វិចារៈ | ការពិចារណា |
| ៣- អធិមោក្ខៈ | ការដាក់ចិត្តស៊ប់ (សន្និដ្ឋាន) |
| ៤- វីរិយៈ | ការឧស្សាហ៍ |
| ៥- បីតិ | ការឆ្អែតចិត្ត |
| ៦- ឆន្ទៈ | ការប្រាថ្នាដើម្បីធ្វើ |



ស្កេនដើម្បីមើលមេរៀន
San Sochea Official

# សព្វចិត្តសាធារណចេតសិក ៧

## ១ - ផស្សចេតសិក (Contact or sense-impression)

ផុស្សតីតិ = ផស្សោ ធម៌ដែលឈ្មោះថា ផស្សៈ ព្រោះអត្ថថា ប៉ះខ្ទប់ ។ ប្រៀបដូចពពៃ ២ ពពៃមួយដូចជាអាយតនៈខាងក្នុង ពពៃមួយទៀតដូចជា អាយតនៈខាងក្រៅ ផស្សៈដូចជាការជល់គ្នានៃពពៃទាំងពីរនោះឯង។

តួនាទីរបស់ផស្សៈ គឺការប៉ះខ្ទប់អារម្មណ៍ដែលចិត្តដឹង និងជាបច្ច័យឲ្យធម៌ ៣ ប្រជុំគ្នាគឺ  អារម្មណ៍ វត្ថុ និងវិញ្ញាណ។

# លក្ខណាទិចតុក្កៈរបស់ ផស្សចេតសិក

១- ផុស្សនលក្ខណោ    មានការប៉ះខ្ទប់ ជាលក្ខណៈ

២- សង្ឃដ្ដនរសោ    មានការធ្វើឲ្យចិត្ត និងអារម្មណ៍ប៉ះខ្ទប់គ្នាជាកិច្ច

៣- សន្និបាតបច្ចុប្បដ្ឋានោ    មានការប្រជុំរវាង អារម្មណ៍ វត្ថុ ចិត្ត ជាអាការប្រាកដ

៤- អាបាថគតវិសយបទដ្ឋានោ    មានអារម្មណ៍មកកាន់គន្លងជាហេតុជិត។

## ២ - វេទនាចេតសិក (Feeling or sensation)

វេទិយតីតិ = វេទនា  ធម្មជាតិណាមែងសោយ (នូវអារម្មណ៍ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វេទនា។

វេទិយតិ អាលម្ពណរសំ អនុភវតិ = វេទនា ធម៌ដែលឈ្មោះថា វេទនា ព្រោះអត្ថថា រលឹកដឹងខ្លួន គឺសោយរសនៃអារម្មណ៍។

**វេទនា** បើពោលដោយលក្ខណៈនៃការសោយអារម្មណ៍មាន ៣ គឺ សុខវេទនា ១ ទុក្ខវេទនា ១ និងអទុក្ខមសុខវេទនា (ឧបេក្ខា)១។ បើពោលតាម ឥន្ទ្រិយមាន ៥ គឺ សុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ និងឧបេក្ខាវេទនា ១

*(ហៅថា សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ជាដើមក៏បាន)* ។

# លក្ខណាទិចតុក្កៈរបស់វេទនាចេតសិក

| | |
|---|---|
| ១ - អនុភវនលក្ខណា | មានការសោយអារម្មណ៍ ជាលក្ខណៈ |
| ២ - វិសយរសសម្ភោគរសា | មានការបរិភោគរសអារម្មណ៍ ជាកិច្ច |
| ៣ - សុខទុក្ខបច្ចុប្បដ្ឋានា | មានសុខនិងទុក្ខ ជាអាការប្រាកដ |
| ៤ - ផស្សបទដ្ឋានា | មានផស្សៈ ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់សុខវេទនា

| | |
|---|---|
| ១- ឥដ្ឋផោដ្ឋញ្ញានុភវនលក្ខណា | មានការសោយនូវផោដ្ឋព្វៈ គួរជាទីប្រាថ្នា ជាលក្ខណៈ |
| ២- សម្បយុត្តានំ ព្រូហនរសា | មានការធ្វើឲ្យសម្បយុត្តធម៌ ចម្រើន ជាកិច្ច |
| ៣- កាយិកអស្សាទបច្ចុប្បដ្ឋានា | មានការត្រេកអរផ្លូវកាយ ជាអាការប្រាកដ |
| ៤- កាយិន្ទ្រិយបទដ្ឋានា | មានកាយបសាទ ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់ទុក្ខវេទនា

| | |
|---|---|
| ១- អនិដ្ឋផោដ្ឋព្វានុភវនលក្ខណា | មានការសោយផោដ្ឋព្វៈ មិនគួរប្រាថ្នា ជាលក្ខណៈ |
| ២- សម្បយុត្តានំ មិលាបនរសា | មានការធ្វើឲ្យសម្បយុត្តធម៌ សៅហ្មង ជាកិច្ច |
| ៣- កាយិកាពាធបច្ចុប្បដ្ឋានា | មានអាពាធផ្លូវកាយ ជាអាការប្រាកដ |
| ៤- កាយិន្ទ្រិយបទដ្ឋានា | មានកាយបសាទ ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់សោមនស្សវេទនា

| | |
|---|---|
| ១- ឥដ្ឋារម្មណានុភវនលក្ខណា | មានការសោយនូវអារម្មណ៍ ជាទីប្រាថ្នា ជាលក្ខណៈ |
| ២- ឥដ្ឋាការសម្ភោគរសា | មានការប្រសព្វនឹងអារម្មណ៍ ដែលគួរប្រាថ្នា ជាកិច្ច |
| ៣- ចេតសិកអស្សាទបច្ចុប្បដ្ឋានា | មានការត្រេកអរផ្លូវចិត្ត ជាអាការប្រាកដ |
| ៤- បស្សទ្ធិបទដ្ឋានា | មានការស្ងប់កាយ ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់ទោមនស្សវេទនា

| | |
|---|---|
| ១- អនិដ្ឋារម្មណានុភវនលក្ខណា | មានការសោយអារម្មណ៍ មិនជាទីប្រាថ្នា ជាលក្ខណៈ |
| ២- អនិដ្ឋាការសម្ភោគរសា | មានការប្រសព្វនឹងអារម្មណ៍ ដែលមិនគួរប្រាថ្នា ជាកិច្ច |
| ៣- ចេតសិកាពាធបច្ចុប្បដ្ឋានា | មានអាពាធផ្លូវចិត្ត ជាអាការប្រាកដ |
| ៤- ឯកន្តេយេវហទយវត្ថុបទដ្ឋានា | មានហទយវត្ថុតែម្យ៉ាង ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់ឧបេក្ខាវេទនា

១- មជ្ឈត្តវេទយិតលក្ខណា មានការសោយអារម្មណ៍ជាកណ្ដាល ជាលក្ខណៈ

២- សម្បយុត្តានំ នាតិឧបព្រូហនមិលាបនរសា មានការរក្សាសម្បយុត្តធម៌ឲ្យចម្រើន និងមិនឲ្យសាបសូន្យជាកិច្ច

៣- សន្តភាវបច្ចុប្បដ្ឋានា មានការស្ងប់ ជាអាការប្រាកដ

៤- និប្បីតិកចិត្តបទដ្ឋានា មានចិត្តដែលមិនប្រកបដោយបីតិជាហេតុជិត។